00846381

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 11 / 09 / 2012
ម៉ោង (Time/Heure): 11:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

002/19-09-2007-ECCC/TC
E1/118

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ៣០ ខែ សីហា ឆ្នាំ ២០១២

## សវនាការលើបញ្ហាសម្បទាបញ្ញាស្មារតីជនជាប់ចោទ - ថ្ងៃទី ១០៥

រៀបចំដោយ: ដាវ អានសាន និង Roger PHILLIPS

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធួ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Roger PHILLIPS, លោក ដាវ អានសាន, លោកស្រី Susan LAMB, |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ចាន់ ដារាវុស្ស, លោក RAYNOR Keith, លោក Tarik ABDULHAK កញ្ញា សុង ឆវ័ន្ត, លោក Salim Nakhjavani, លោក ពេជ្រ សម្បត្តិ, លោក Dale Lysak, លោក Salim Nakhjavani |

| |
|---|
| ជនជាប់ចោទ៖ អៀង ធីរិទ្ធ (ចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោម) និង<br>អៀង សារី (ចូលរួមពីបន្ទប់ឃុំខ្លួនខាងក្រោម) |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង ធីរិទ្ធ៖ លោក ផាត់ ពៅស៊ាង, លោកស្រី Diana ELLIS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោក សំ សុគង់, លោកស្រី Elisabeth SIMONNEAU-FORT, លោកស្រី Beini YE, លោក វ៉េន ពៅ, លោក ហុង គីមសួន, លោកស្រី ស៊ីន សូវន, លោកស្រី ចេត វ៉ាន់លី, លោក ឡោ ជុនធី, លោកស្រី គ្រីស្ទីន ម៉ាទីណូ, លោកស្រី ទី ស្រីណា |
| អ្នកជំនាញ៖ លោក ហួត លីណា, លោក Seena FAZEL, លោក John A. CAMPBELL<br>សាក្សី៖ លោកស្រី ចក ធីតា |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Simon MEISENBERG, លោក Yiqiang LIU, កញ្ញា Sonia MESSAOUDI |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១៦.២០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកវេលាល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៤០ | បញ្ចប់ម៉ោង៖ ១៥.០០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៤ ម៉ោង | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| រំលឹកអំពីប្រវត្តិនីតិវិធីពាក់ព័ន្ធ | អង្គជំនុំជម្រះ | ១០.៣៧ | ១០.៤៩ |
| ការតាំងសំណួរដល់អ្នកជំនាញ | អង្គជំនុំជម្រះ | ១០.៥០ | ១១.២៧ |
| ការតាំងសំណួរដល់សាក្សី លោកស្រី ចក ធីតា | អង្គជំនុំជម្រះ | ១១.២៨ | ១៤.១១ |
| | មេធាវីការពារក្តី អៀង ធីរិទ្ធ | ១៤.១៥ | ១៥.៥១ |
| | តំណាងសហព្រះរាជអាជ្ញា | ១៥.៥១ | ១៦.០៧ |
| | មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១៦.០៨ | ១៦.១៦ |

## <u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>

### <u>រំលឹកអំពីប្រវត្តិនីតិវិធីពាក់ព័ន្ធ</u>

ប្រធានអង្គជំនុំជម្រះប្រកាសអំពីប្រវត្តិនីតិវិធីពាក់ព័ន្ធនឹងដំណើរការនីតិវិធីលើបញ្ហាសម្បទា និងបញ្ហាស្មារតី ជនជាប់ចោទ អៀង ធីរិទ្ធ ចាប់ពីការតែងតាំងអ្នកជំនាញសាស្ត្រាចារ្យ John A. Campbell, សវនាការរបស់អង្គសង លើបញ្ហាបញ្ហាស្មារតី ជនជាប់ចោទ អៀង ធីរិទ្ធ, សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល, ការព្យាបាល រួមទាំងកម្មវិធីលើកកម្ពស់បញ្ហាស្មារតី ជាបន្តបន្ទាប់ដល់ជនជាប់ចោទ។

### <u>ការតាំងសំណួរដល់អ្នកជំនាញ</u>

អង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួនដល់អ្នកជំនាញ Seena FAZEL និងអ្នកជំនាញ John A. CAMPBELL និង លោក ហួត លីណា។

### <u>ការមកដល់របស់សហមេធាវីអន្តរជាតិការពារក្តី អៀង ធីរិទ្ធ លោកស្រី Diana ELLIS</u>

លោកស្រី Diana ELLIS បានមកដល់បន្ទប់សវនាការនៅម៉ោង ១០.៥២ នាទី ដោយសារតែមានការពន្យាពេលជើងយន្តហោះ។

### <u>ការតាំងសំណួរដល់សាក្សី លោកស្រី ចក ធីតា</u>

ប្រធានអង្គជំនុំជម្រះតាំងសំណួរបឋមមួយចំនួន ដល់សាក្សី លោកស្រី ចក ធីតា និងប្រកាសប្រាប់អំពីសិទ្ធិ និងករណីយកិច្ចរបស់សាក្សី។ ជាបន្តបន្ទាប់ មេធាវីការពារក្តី, តំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានតាំងសំណួរជាបន្តបន្ទាប់ដល់សាក្សី អំពីគុណវុឌ្ឍិ, ការអប់រំ, កម្រិតជំនាញ, បទពិសោធន៍ការងារ, ប្រវត្តិ និងវិធីសាស្ត្រព្យាបាល, និងរបាយការណ៍វេជ្ជសាស្ត្រដែលពាក់ព័ន្ធដល់សាក្សីលោកស្រី ចក ធីតា។

### <u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in France |
|---|---|---|---|---|---|---|---|

| | | | | | | | |
|---|---|---|---|---|---|---|---|
| N/A | E138 | 00753929-00753980 00753479-00753508 00757429-00757462 | [កែតម្រូវ ១] សេចក្ដីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ | P | | | |
| N/A | E138/1/7/4 | 00787292-00787304 00786506-00786513 | របាយការណ៍ទាក់ទងនឹងលោកស្រី អៀង ធីរិទ្ធ ដាក់ជូនតាមសំណើ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ២០១២ | S | | | |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- បង្គាប់ឱ្យអង្គភាពគាំពារសាក្សីនិងអ្នកជំនាញ នាំអ្នកជំនាញ និងសាក្សី ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់វិញ និងបង្គាប់ឱ្យនាំអ្នកជំនាញត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩.០០ ព្រឹក នៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១២ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង ធីរិទ្ធ និង អៀង សារី ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទ អៀង ធីរិទ្ធ ត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩.០០ ព្រឹក នៅថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១២។

**កាលបរិច្ឆេទបន្តសវនាការ៖**

សវនាការនឹងបន្តនៅថ្ងៃ សុក្រ ទី ៣១ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១២

ក្រឡាបញ្ជី ... ក្រឡាបញ្ជី

ដាច អ... Roger PHILLIPS